ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៣៨

ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០

**សាលដីកា**

លេខ ៤៤៤ "VI"

ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១

ok

# សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១

ដោយអង្គជំនុំជម្រះមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកជំទាវ [redacted] ជាចៅក្រម

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-ឯកឧត្តម [redacted] ជាចៅក្រម

៥-លោកជំទាវ [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

លោកជំទាវ [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ១០៤ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] ចំពោះសាលដីកាព្រហ្មទណ្ឌលេខ៣៤ក្រVសស ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖



Scanned with CamScanner

-**បុគ្គលម្ដីងសាទុក្ខឈ្មោះ** [redacted] **ទីរៈ** ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ មានមុខរបរ មិនពិតប្រាកដ មានទីកន្លែងកំណើតនៅភូមិអណ្ដូងស្វាយ ឃុំអណ្ដូងស្វាយ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ឪពុកឈ្មោ [redacted] (ស) ម្ដាយ ឈ្មោ [redacted]) ទោសពីមុនគ្មាន ។

ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៦៤៣ ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៧ ។

**ជាប់ចោទពីអំពើលួចដោយមានស្ថានទម្ងន់ទោស និងបទប្រើប្រាស់អាវុធខុសច្បាប់** ប្រព្រឹត្តនៅភូមិរកាកំបុត ឃុំរកាកំបុត ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ មាត្រា៣៥៧ ក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្ដីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ។

-មានលោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

**-ដើមបណ្ដឹងរដ្ឋប្បវេណី**

១-ឈ្មោះ [redacted] ចិន ភេទប្រុស អាយុ ៦២ឆ្នាំ ជាតិខ្មែរ មានលំនៅសព្វថ្ងៃនៅភូមិរលួសខាងកើត ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

២-ឈ្មោះ [redacted] ប៊ុនរ៉ុង ភេទប្រុស អាយុ ៤៦ឆ្នាំ ជាតិខ្មែរ មានលំនៅសព្វថ្ងៃនៅភូមិរលួសខាងកើត ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ០៨ ព្រឹក ស្ថិតនៅភូមិរកាកំបុត ឃុំរកាកំបុត ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានករណីលួចមានស្ថានទម្ងន់ទោសដែលបង្កឡើងដោយជនមិនស្គាល់អត្តសញ្ញាណបានធ្វើសកម្មភាពកាច់សោរកម៉ូតូចំនួន០១គ្រឿង ម៉ាកហុងដាC-១២៥ សេរីឆ្នាំ២០១៧ ពណ៌ខ្មៅគ្មានស្លាកលេខ ដែលជារបស់ជនរងគ្រោះឈ្មោ [redacted] ចិន ភេទប្រុស អាយុ ៦២ឆ្នាំ ហើយបានជិះគេចខ្លួនបាត់។ លុះក្រោយមក សមត្ថកិច្ចបានធ្វើការស្រាវជ្រាវនិងកំណត់មុខសញ្ញាឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] វីរៈ ភេទប្រុស អាយុ ២៧ឆ្នាំ ព្រមទាំងដកហូតបានម៉ូតូខាងលើនិងអាវុធខ្លីចំនួន ០១ ដើម។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ៦៦ “ខ” ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ផ្ដន្ទាទោសឈ្មោះ [redacted] វីរៈ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ (ដូចមានសាវតារជាតិខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ។

**ពីអំពើលួចដោយមានស្ថានទម្ងន់ទោស និងបទប្រើប្រាស់អាវុធខុសច្បាប់** ប្រព្រឹត្តនៅភូមិរកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ



Scanned with CamScanner

២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ , មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

២-វត្ថុតាងរួមមានទូរស័ព្ទដៃម៉ាក Camfone Model: P600 ពណ៌បៃតង ចំនួន ០១គ្រឿង , នាឡិកាដៃចំនួន ០១ និងសោរម៉ូតូម៉ាកហុងដា ចំនួន ០១ ត្រូវប្រគល់ឱ្យម្ចាស់ដើមឈ្មោ[redacted]រៈ វិញ។

៣-សាលក្រមនេះជំនុំជម្រះនិងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោ[redacted] វីរៈ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ចិន និងឈ្មោះ [redacted]ប៊ុនរ៉ុង ។

បើកផ្លូវប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**-បានឃើញ** បណ្តឹងឧទ្ធរណ៍លេខ ២៣៧៣ រ.ម ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោ[redacted] **វីរៈ** ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៦ “ខ” ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០១៨ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

**-បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ ៣៤ក្រV“សស” ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ២៣៧៣ រ.ម ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោ[redacted]ៈ ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៦ “ខ” ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តសៀមរាបទុកជាបានការទាំងមូលដដែល ដោយគ្រាន់តែកែប្រែថា តាមមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌវិញ។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមនីតិវិធី។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]វីរៈ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

**-បានឃើញ** បណ្តឹងសាទុក្ខលេខ ១០៤ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] **វីរៈ** ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣៤ក្រVសស ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានធ្វើសេចក្តីរាយការណ៍



Scanned with CamScanner

-តំណាងមហាអយ្យការអមតុលាការកំពូលបានសន្និដ្ឋានថា តាមការបង្ហាញអង្គហេតុរបស់តុលាការអង្គសេចក្តីឃើញថា ជនជាប់ចោទត្រូវបានត្រូវបានសមត្ថកិច្ចចាប់ខ្លួនបានជាក់ស្តែង នៅពេលដែលជនជាប់ចោទកំពុងប្រព្រឹត្តបទល្មើស ដោយឡើងជិះម៉ូតូរបស់ជនរងគ្រោះ។ តែបែរជាឆ្លើយដោះសាថា ខ្លួនមិនដឹងថាឈ្មោះ ភា បានម៉ូតូមកពីណាទេ ទើបខ្លួនឡើងជិះជាមួយ។ នៅខណៈពេលឃើញសមត្ថកិច្ចជិះដេញតាម ខ្លួនភ័យពេកក៏រត់តែម្តង ។ ចម្លើយដោះសានេះមិនមានមូលហេតុដូចក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ដែលជាហេតុអាចឱ្យតុលាការកំពូលបដិសេធសាលដីកាសាលាឧទ្ធរណ៍នោះឡើយ។ហេតុដូច្នេះតំណាងមហាអយ្យការប្តឹងចំពោះតុលាការកំពូលសុំឱ្យទទួលបណ្តឹងសាទុក្ខលេខ ១០៤ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] វីរៈ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសទៅនឹងគតិច្បាប់ ។ សុំតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣៤ ក្រV "ស.ស" ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល ។

-លោក [redacted] បូរ៉ា ជាមេធាវីការពារឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា រឿងកើតឡើងនៅសៀមរាប កូនក្តីខ្លួនបានសារភាព សាលដីកាសាលាឧទ្ធរណ៍មិនមានភាពស៊ីចង្វាក់គ្នា ម្ចាស់ម៉ូតូមិនបានចង្អុលបង្ហាញ សំអាងហេតុមិនច្បាស់ទេ ។

<u>សំណូមពរ</u> ៖ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចនិងពិនិត្យឡើងវិញ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាននិងប្តឹងសុំរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ
## តុលាការកំពូល

**១-យល់ឃើញថា** បណ្តឹងសាទុក្ខលេខ ១០៤ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] វីរៈ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្តីនេះមកជំនុំជម្រះបានតាម បទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧, មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២-យល់ឃើញថា** ការដែលមេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា សាលាឧទ្ធរណ៍ពុំបានធ្វើសំអាងហេតុច្បាស់លាស់ ដែលមានន័យដូចទៅនឹងការខ្វះសំអាងហេតុ ដោយមូលហេតុថាសាលាឧទ្ធរណ៍ពុំបានបង្ហាញឱ្យឃើញពីធាតុផ្សំអគ្គនោម័តនៃបទល្មើស គឺជាការមិនត្រឹមត្រូវទេ ពីព្រោះថាសាលាឧទ្ធរណ៍បានសម្រេចសេចក្តីផ្អែកលើចម្លើយរបស់ជនជាប់ចោទ ដែលបានឆ្លើយនៅដំណាក់កាលស៊ើបសួរ



Scanned with CamScanner

ដែលមានភាពស៊ីចង្វាក់ជាមួយនឹងចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ដា ព្រមទាំងការចាប់ខ្លួនជនជាប់ចោទក្នុងស្ថានភាពជាករណីបទល្មើសជាក់ស្តែង បន្ទាប់ពីបានបាញ់មកលើអាជ្ញាធរមានសមត្ថកិច្ចចំនួន០៤ គ្រាប់។ ភស្តុតាងទាំងនេះមានភាពធួនល្មមអាចឱ្យកំណត់ពីអត្ថិភាពពិរុទ្ធភាពលើជនជាប់ចោទហួសពីវិមតិសង្ស័យហើយ ។

**៣-យល់ឃើញថា** ការដែលមេធាវីការពារជនជាប់ចោទបានសន្និដ្ឋានថា អំពើរបស់ជនជាប់ចោទពាក់ព័ន្ធនឹងការប្រើប្រាស់កាំភ្លើងត្រូវទទួលការផ្តន្ទាទោសតាមមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ មិនមែនមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌទេ ដោយសារតែមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវចែងពីទោសស្រាលជាង គឺជាការមិនត្រឹមត្រូវទេ ដោយហេតុថា ជនជាប់ចោទបានកាន់កាប់និងប្រើប្រាស់កាំភ្លើងម៉ាក កា៥៩ ដោយមិនមានការអនុញ្ញាត ហើយអំពើរបស់ជនជាប់ចោទបានកើតឡើងនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលក្រមព្រហ្មទណ្ឌកំពុងមានអានុភាពអនុវត្ត ។ ហេតុនេះ តុលាការកំពូលគ្រាន់តែកែតម្រូវឈ្មោះបទល្មើសពី "បទប្រើប្រាស់អាវុធខុសច្បាប់" មកជាបទ "កាន់កាប់អាវុធដោយគ្មានការអនុញ្ញាត" ឱ្យបានត្រឹមត្រូវតាមឈ្មោះបទល្មើសកំណត់ដោយមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌប៉ុណ្ណោះ ។

**៤-យល់ឃើញថា** ការដែលតំណាងមហាអយ្យការអមបានសន្និដ្ឋានស្នើសុំឱ្យតុលាការកំពូលសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដែលតុលាការកំពូលពិចារណាឃើញថា គឺជាសេចក្តីសន្និដ្ឋានមានមូលដ្ឋានសំអាងត្រឹមត្រូវសមស្រប និងស្របតាមផ្នែកសំអាងហេតុត្រង់ចំណុចផ្សេងទៀតរបស់តុលាការកំពូលដែរ ។

**៥-យល់ឃើញថា** បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] វីរៈ ធ្វើឡើងមិនមានមូលហេតុនៃបណ្តឹងសាទុក្ខស្របតាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

**៦-យល់ឃើញថា** សាលដីកាព្រហ្មទណ្ឌលេខ ៣៤ ក្រV "សស" ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមច្បាប់ហើយ ។ លើកលែងតែការកំណត់ ឈ្មោះបទល្មើសថាជា "បទប្រើប្រាស់អាវុធខុសច្បាប់" ដែលតុលាការកំពូលត្រូវកែតម្រូវ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

**១-បដិសេធ**បណ្តឹងសាទុក្ខលេខ ១០៤ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] វីរៈ ។



Scanned with CamScanner

**២-តម្កល់**សាលដីកាព្រហ្មទណ្ឌលេខ ៣៤ ក្រV "សស" ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដោយកែប្រែឈ្មោះបទល្មើសពី "បទប្រើប្រាស់អាវុធខុសច្បាប់" មកជា "បទកាន់កាប់អាវុធដោយគ្មានការអនុញ្ញាត" វិញ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ។

ឯកឧត្តម [redacted] ជាប្រធាន

លោកជំទាវ [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

លោកជំទាវ [redacted] ជាចៅក្រម

លោកស្រី [redacted] ក្រឡាបញ្ជី

---

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

ថ្ងៃ សុក្រ ១២ រោច ខែមគសិរ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃ សុក្រ ១២ រោច ខែមគសិរ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១

**ប្រធានអង្គជំនុំជម្រះ**

[redacted]



Scanned with CamScanner